# ខ្លឹមសារសង្ខេបអត្ថបទស្រាវជ្រាវ ស្តីពី ញៀនស្រា ជាការដោះសារ រួចផុតពីបទឧក្រិដ្ឋ

L. S. Tao, *Alcoholism As a Defense to Crime*, 45 Notre Dame L. Rev. 68 (1969)
Available at: http://scholarship.law.nd.edu/ndlr/vol45/iss1/11

១. អ្នកផឹកស្រា អាចស្រវឹងធម្មតា ស្រវឹងជោគ (gross intoxication) ញៀន ឬ ក្លាយជាអ្នកប្រមឹក (sober)។ អ្នកប្រមឹកខ្លះ អាចត្រូវបានចាត់ថា មានរោគចិត្ត (Mental Disease) អាចចាត់ថាឆ្កួតបណ្ដោះអាសន្ន (temporary insane)។ ទោះបីជាយ៉ាងនេះក្ដី មិនអាចចាត់ថាឆ្កួតរហូតទេ។ បុគ្គលអាច ធ្វើខ្លួនឲ្យជាពីស្រាបាន។ នៅពេលមុនពេលផឹកស្រា ស្មារតីរបស់គាត់នៅល្អ និងដឹងខុសត្រូវ។

២. មុនពេលផឹក គាត់មានស្មារតី ដែលបង្ហាញថាគាត់មានឆន្ទៈ (voluntary) ធ្វើសកម្មភាពផឹកស្រវឹងក្នុងទីសាធារណៈ បំពេញជាតុផ្សំសំភារៈ *(Actus Reus)* ដែលជាបទល្មើសហាមឃាត់ និងជាប្រភេទបទល្មើស Strict Liability (ទំ.៧១) ។ ដូចនេះ គាត់ត្រូវទទួលខុសត្រូវ។ បញ្ហា វានឹងកើតមានថា នាពេលស្រវឹង គាត់បានប្រព្រឹត្តបទល្មើសមួយ តើគាត់ត្រូវរួចខ្លួនពីការទទួលខុសត្រូវ ដោយសារ ថាគាត់ស្រវឹង មិនដឹងអ្វីបានដែរទេ?

៣. អ្នកផឹក ធ្លាប់មានបទពិសោធន៍ ស្រវឹងបង្កគ្រោះថ្នាក់ចរាចរ។ នៅពេលផឹក គាត់ដឹងថា បើស្រវឹងគាត់បើកឡាន គាត់នឹងប្រព្រឹត្តបទល្មើស តែគាត់នៅតែផឹក។ ស្ថានភាពអ្នកញៀន ទីមួយ មិនអាចទប់ខ្លួនមិនឲ្យផឹក និងទី២ បើបានផឹកហើយ គឺនៅតែផឹកបន្តរហូតដល់ស្រវឹង (ទំ. ៧៦)។ នេះបង្កដោយខ្លួនគាត់ (Self-induced intoxication)។ វាមិនមែនជាកត្តាខាងក្រៅ ដូចជាការបង្ខំគាត់ឲ្យផឹកទេ។ក្នុងករណីនេះ បើបង្កគ្រោះថ្នាក់ដល់ស្លាប់ គាត់នឹងទទួលខុសត្រូវពីបទមនុស្សឃាតដោយធ្វេសប្រហែស (Recklessness) ទំ.៧៩។ ជនល្មើស អាចលើកយកភាពស្រវឹងមកដោះសារ តែគាត់ត្រូវបង្ហាញថា ១. គាត់ស្រវឹងខ្លាំង ហើយមិនអាចគ្រប់គ្រងសកម្មភាពផ្ទាល់ខ្លួនបាន និងទី២ ភាពស្រវឹងនេះឯង ជាដើមចមចំបងនាំឲ្យប្រព្រឹត្តបទល្មើសដែលត្រូវបានចោទ (Irresistible Impulse),ទំ.៨៨។

៤. មនុស្សក្នុងស្ថានភាពស្រវឹង ពុំអាចបង្កើតជាតុអត្តនោម័ត នៃបទល្មើសទាមទារចេតនាជាក់លាក់ (Specific Intent Offence) ដូចជាបទលួច(កង់) ទេ ដោយសារ ក្នុងពេលស្រវឹងជោគ គាត់មិនដឹងខ្លួនថាគាត់មានចេតនាយករបស់គេជារហូត ឬសូម្បីថា កង់ ឬជាស្អី ក៏មិនដឹងផងពេលខ្លះ។

៥. ជាទូទៅ តុលាការកម្រនឹងឲ្យអ្នកស្រវឹង រួចផុតពីការទទួលខុសត្រូវទាំងស្រុងក្នុងរឿងព្រហ្មទណ្ឌ។ ក៏ប៉ុន្តែ វាអាចជាស្ថានសម្រាលទោស។

**<u>កំណត់សំគាល់</u>**៖ ១. ជំងឺឆ្កួតមិនអាចព្យាបាលឲ្យជាបានទេ។ នៅពេលប្រព្រឹត្តបទល្មើស មនុស្សឆ្កួត ឬវិកលចរិត មិនដឹងថាខ្លួនធ្វើអ្វីផង ឬមិនដឹងថាអ្វីខ្លួនធ្វើ ខុសឬក៏ត្រូវដែរ។ នេះ មិនបានបំពេញជាតុផ្សំអត្តនោម័តនៃបទល្មើស។ ក្នុងរឿងនេះ គេចាត់ថាមិនមានបទល្មើសកើតឡើង ដូចនេះមិននាំឲ្យមានការទទួលខុសត្រូវទេ។ តុលាការមិនដាក់គុកមនុស្សឆ្កួតទេ ក៏ប៉ុន្តែបញ្ជាឲ្យឃុំខ្លួន ឬ ដាក់ក្នុងមន្ទីរពេទ្យឆ្កួត។ អ្នកគ្រប់គ្រង ត្រូវទទួលខុសត្រូវសំណងរដ្ឋប្បវេណី ចំពោះអំពើនៃមនុស្សឆ្កួត។ ២. ក្នុងន័យនេះហើយ ក៏ដូចគ្នានឹងករណីញៀនស្រា ដែលអ្នកញៀនមានរោគចិត្ត ដែលនាំឲ្យគាត់ប្រព្រឹត្តល្មើសមិនរាងចាល ក៏មិនត្រូវដាក់គុក

គាត់ដែរ ព្រោះគាត់នៅតែមិនអាចកែខ្លួនបាន។ ៣. ជាតុផ្សំនៃបទល្មើសមាន៖ ១. សកម្មភាពស្ម័គ្រចិត្ត ដែលការស្ម័គ្រចិត្តជាផ្នែកមួយនៃជាតុផ្សំសំភារៈនិង ជាតុអត្តនោម័ត គឺមានជាចេតនា (ធ្វើដើម្បីអ្វីមួយ) ដូចជាដើម្បីឲ្យជនរងគ្រោះស្លាប់។